**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~x~~~~~~~~

# សុន្ទរកថា
# ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
# និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
# ក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោក
**ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ នៅទីស្តីការក្រសួងពាណិជ្ជកម្ម**

- *ឯកឧត្តម **WILLIAM A. HEIDT** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា!*
- *ឯកឧត្តម **GEORGE EDGAR** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា!*
- *ឯកឧត្តម **KUMAMARU YUJI** ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា!*
- *ឯកឧត្តម **សោម សុគន្ធ** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយឥតឧបមា និងសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោក នាថ្ងៃនេះ។

ជារៀងរាល់ឆ្នាំនៅថ្ងៃទី ២៦ ខែមេសា សមាជិកទាំងអស់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក តែងតែប្រារព្ធទិវាកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃគំនិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់មនុស្សជាតិ ក៏ដូចជាការដើរតួយ៉ាងសំខាន់របស់វិស័យកម្មសិទ្ធិបញ្ញាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ដើម្បីលើកកម្ពស់ចំណេះដឹង និងផ្សព្វផ្សាយបន្ថែមអំពីអត្ថប្រយោជន៍នៃវិស័យកម្មសិទ្ធិបញ្ញា ប្រទេសជាសមាជិកខ្លះបានរៀបចំការតាំងពិពរណ៍នានា ក៏ដូចជាសិក្ខាសាលា ជូនដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវដែលមានចំណាប់អារម្មណ៍លើវិស័យនេះ។

ប្រធានបទសម្រាប់ទិវាកម្មសិទ្ធិបញ្ញាពិភពលោកក្នុងឆ្នាំនេះគឺ "Digital Creativity : Culture Reimagined" ដែល Digital Creativity គឺពាក់ព័ន្ធនឹងការច្នៃប្រឌិត និងការបង្កើតថ្មីបែបឌីជីថល ហើយ Reimaging Culture ពាក់ព័ន្ធនឹងការបង្កើត ការទាញយក និងការឲ្យតម្លៃផ្នែកហិរញ្ញវត្ថុ ដែលកិច្ចការទាំងនេះមានឧបសគ្គជាច្រើន ដូច្នេះដើម្បីជម្រុញឲ្យសិល្បៈករ និងផលិករនៅតែបង្កើតស្នាដៃថ្មី ត្រូវតែមានការលើកទឹកចិត្តសមរម្យដល់ពួកគាត់។ ខ្ញុំសូមជម្រាបជូនថា ស្នាដៃវប្បធម៌រួមមាន ខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ បទភ្លេង សៀវភៅ សិល្បៈ និងការកំសាន្ត អាចត្រូវបានដំណើរការ និងប្រើប្រាស់ដោយគ្មានដែនកំណត់នៅទូទាំងពិភពលោក។ បច្ចេកវិទ្យាឌីជីថលបានផ្តល់ភាពងាយស្រួលជូនដល់សិល្បៈករ ផលិករ ដើម្បីឲ្យពួកគេអាចបង្ហាញនូវការច្នៃប្រឌិតរបស់ពួកគេ និងដើម្បីអាចសហការរវាង
~~~~~~~

វប្បធម៌នៃបណ្តាប្រទេសផ្សេងៗ។ ដូចនេះ វាពិតជាមានការចាំបាច់ណាស់ក្នុងការបង្កើតឲ្យមានប្រព័ន្ធកម្មសិទ្ធិបញ្ញាដែលមានភាពបត់បែន និងមានលក្ខណៈសមស្រប ដែលអាចធានាឲ្យសិល្បករ និងភាគីពាក់ព័ន្ធដទៃទៀត ទទួលបាននូវការលើកទឹកចិត្តអំពីស្នាដៃរបស់ខ្លួន។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាទីមេត្រី!*

ពីមួយថ្ងៃទៅមួយថ្ងៃ ពិភពលោកមានការប្រែប្រួល និងបោះជំហ៊ានទៅមុខយ៉ាងលឿន ហេតុដូចនេះហើយបណ្តាប្រទេសទាំងអស់ត្រូវតែតាមដានឲ្យជាប់អំពីការវិវឌ្ឍថ្មីៗទាំងនេះ។ ជាក់ស្តែង ដើម្បីដើរឲ្យទាន់នូវការអភិវឌ្ឍនេះ កម្ពុជាបានអនុម័តនូវច្បាប់ ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក្នុងឆ្នាំ២០០៣ ដែលច្បាប់នេះបានផ្តល់នូវកិច្ចការពារសម្រាប់អ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ដើម្បីគ្រប់គ្រងនូវស្នាដៃរបស់ខ្លួនពាក់ព័ន្ធនឹងមាតិកាឌីជីថល និងការប្រើប្រាស់ស្នាដៃទាំងនោះលើប្រព័ន្ធអ៊ីនធឺណែត។ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យកម្មសិទ្ធិបញ្ញាជាវិស័យចម្បងក្នុងចំណោមវិស័យសំខាន់ៗដទៃទៀត ហើយកម្ពុជាក៏បាននឹងកំពុងសិក្សាដើម្បីចូលជាសមាជិកនៃអនុសញ្ញាផ្សេងៗទៀត របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកផងដែរ។ ខ្ញុំសូមទាញអារម្មណ៍របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អំពីភាពជោគជ័យផ្នែកកម្មសិទ្ធិបញ្ញារបស់កម្ពុជានាពេលថ្មីៗនេះ ដែលគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្រោមការដឹកនាំពីក្រសួងពាណិជ្ជកម្ម និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំការប្រគុំតន្ត្រី "ពេលវេលាដែលត្រូវតបស្នង" ជូនដល់អធិរាជសម្លេងមាស ស៊ិន ស៊ីសាមុត ក្នុងគោលបំណងស្វែងរកការឧបត្ថម្ភដល់ក្រុមគ្រួសាររបស់លោក ស៊ិន ស៊ីសាមុត និងអ្នកស្រី រស់ សេរីសុទ្ធា ក៏ដូចជាសិល្បៈករជំនាន់ដើមដែលនៅរស់រានមានជីវិតក្នុងជីវភាពលំបាក រួមទាំងឧបត្ថម្ភទៅដល់មន្ទីរពេទ្យគន្ធបុប្ផា និងមន្ទីរពេទ្យព្រះអង្គឌួង ហើយនឹងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីសារៈប្រយោជន៍ និងកិច្ចការពារកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាទីមេត្រី!*

នៅក្នុងថ្ងៃដ៏វិសេសវិសាលនេះ យើងខ្ញុំមានកិត្តិយសណាស់ ដោយមានវត្តមានរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ឯកឧត្តមឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងការប្រារព្ធទិវាកម្មសិទ្ធិបញ្ញាពិភពលោកជាមួយយើងនាថ្ងៃនេះ។ នេះគឺជាលើកទីបីហើយ ដែលយើងបានប្រារព្ធទិវានេះឡើង ក្នុងគោលបំណងបង្ហាញអំពីការប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់របស់កម្ពុជាលើវិស័យកម្មសិទ្ធិបញ្ញា ដែលវិស័យនេះត្រូវបានចាត់ទុកថាជាផ្នែកមួយដ៏មានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍ។ នាពេលបន្តិចទៀតនេះ យើងនឹងបានស្តាប់ការធ្វើបទបង្ហាញមួយចំនួន ក្នុងបរិបទផ្សេងៗគ្នា ពីសំណាក់វាគ្មិនកិត្តិយសដែលជាតំណាងមកពី អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន (JPO) តំណាងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) អនុព័ន្ធកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុបប្រចាំតំបន់ តំណាងរបស់គម្រោងសហភាពអឺរ៉ុប-អាស៊ានដើម្បីការពារកម្មសិទ្ធិបញ្ញា តំណាងរបស់សមាគមន៍ភាពយន្ត និងតំណាងរបស់សភាពាណិជ្ជកម្មសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាទីមេត្រី!*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកឡើងបន្តិចអំពីកិច្ចព្រមព្រៀងភាពជាដៃគូអន្តរទ្វីបប៉ាស៊ីហ្វិក Trans-Pacific Partnership (TPP) ដែលមានផលប៉ះពាល់មួយចំនួនមកលើវិស័យកម្មសិទ្ធិបញ្ញារបស់កម្ពុជា។ កិច្ចព្រមព្រៀងនេះ បានបង្កើតឲ្យមានកិច្ចការពារកាន់តែរឹងមាំបន្ថែមទៀតសម្រាប់ ប្រកាសនីយបត្រតក្កកម្ម ម៉ាក និងសិទ្ធិអ្នកនិពន្ធ ដោយឈរលើកិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញាដែលមានស្រាប់ រួមមាន ១. កិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPS) ២. អនុសញ្ញាស្តីពី សិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ៣.អនុសញ្ញាស្តីពី សិទ្ធិអ្នកសម្តែង ហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និង ៤. អនុសញ្ញាស្តីពី កិច្ចសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម។ ហេតុដូចនេះហើយ កម្ពុជាត្រូវតែធ្វើការអង្កេតឲ្យបានជិតដល់ទៅលើការវិវឌ្ឍរបស់ TPP និងធានាឲ្យបានថាការធ្វើពាណិជ្ជកម្មរបស់យើងដើរស្របទៅតាមនិន្នាការនេះ។

ជាទីបញ្ចប់ ខ្ញុំសូមផ្តល់ពេលវេលាបន្ថែមដល់វាគ្មិនកិត្តិយសរបស់យើងដែលនឹងត្រូវធ្វើបទបង្ហាញ និងចំនាប់អារម្មណ៍ ទាក់ទងនឹងទិវាកម្មសិទ្ធិបញ្ញានេះ។ មួយវិញទៀត អ្នកចូលរួមទាំងអស់នឹងមានឱកាសទទួលបាននូវសំបុត្រទស្សនាខ្សែភាពយន្តហូលីវូដថ្មីបំផុត ពីក្រុមហ៊ុន Westec Media Limited (WML) នៅរោងភាពយន្ត Legend Cinema នាល្ងាចនេះ។

*ខ្ញុំសូមប្រកាសបើកទិវាកម្មសិទ្ធិបញ្ញាចាប់ពីពេលនេះតទៅ! សូមអរគុណ !*